ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
លេខ : ....៨.៨..ប...ស.ស.ស.....

សេចក្តីជូនដំណឹង
ស្តីពី
ការជ្រើសរើសអ្នកជំនាញ ១២៥ នាក់
ដើម្បីបម្រើការងារនៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនដល់សាធារណជន និងនិស្សិតជ្រាបថា ដើម្បីពង្រឹងនិងពង្រីកការប្រើប្រាស់បច្ចេកវិទ្យាក្នុងការផ្តល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរ ក្នុងទិសដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ជាពិសេសដើម្បីជានាឱ្យបានភាពជោគជ័យនៃការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលនៅកម្ពុជា ក្រសួងត្រូវការជ្រើសរើសអ្នកជំនាញចំនួន **១២៥នាក់** សម្រាប់បម្រើការងារនៅទីស្តីការក្រសួង តាមជំនាញដូចខាងក្រោម៖

- **អ្នកជំនាញបច្ចេកវិទ្យាពពក** (Cloud Technology) ចំនួន ១៥នាក់
- **អ្នកជំនាញមជ្ឈមណ្ឌលទិន្នន័យ** (Data Center) ចំនួន ១៥នាក់
- **អ្នកជំនាញបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត** (Artificial Intelligence - AI) ចំនួន ១៥នាក់
- **អ្នកជំនាញអភិវឌ្ឍសុសវែរ** (Software Development) ចំនួន ១៥នាក់
- **អ្នកជំនាញវិទ្យាសាស្ត្រទិន្នន័យ** (Data Science) ចំនួន ១៥នាក់
- **អ្នកជំនាញសន្តិសុខសាយប័រ** (Cybersecurity) ចំនួន ១៥នាក់
- **អ្នកជំនាញបច្ចេកវិទ្យាប្លុកឆេន** (Blockchain Technology) ចំនួន ១៥នាក់
- **អ្នកជំនាញហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍** (Telecommunications Infrastructure) ចំនួន ២០នាក់។

១. លក្ខខណ្ឌនៃការជ្រើសរើស

- បេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឡើងទៅ ស្របតាមជំនាញជ្រើសរើស
- មានចំណេះដឹងភាសាអង់គ្លេសអាចប្រើការបាន
- មានឆន្ទៈ និងក្រមសីលធម៌បំពេញការងារ
- មានភាពស្មោះត្រង់ និងយកចិត្តទុកដាក់ចំពោះការងារ
- មានភាពអត់ធ្មត់ តស៊ូ និងឧស្សាហ៍ព្យាយាម
- មានសមត្ថភាពបំពេញការងារដោយឯករាជ្យ និងការងារជាក្រុម
- មានគំនិតផ្តួចផ្តើម និងច្នៃប្រឌិត
- ទទួលយកការបណ្តុះបណ្តាលចំណេះដឹងបន្ថែម
- គុណវុឌ្ឍិផ្សេងទៀតតាមជំនាញនីមួយៗ ដែលភ្ជាប់មកជាមួយសេចក្តីជូនដំណឹងនេះ។

២. តារកិច្ច និងការទទួលខុសត្រូវ

សូមបេក្ខជនមើលនៅក្នុងផ្នែកការកិច្ចនិងទំនួលខុសត្រូវសំខាន់ៗ តាមជំនាញនីមួយៗ ដែលភ្ជាប់មកជាមួយសេចក្តីជូនដំណឹងនេះ។

៣. ប្រាក់បៀវត្ស និងអត្ថប្រយោជន៍

- ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែស្របតាមមុខតំណែង សមត្ថភាព បទពិសោធ និងគុណវុឌ្ឍិរបស់បេក្ខជន
- ទទួលបានចំណេះដឹង និងជំនាញឯកទេសវិជ្ជាជីវៈបន្ថែមតាមរយៈការបណ្តុះបណ្តាល ការអនុវត្តការងារជាក្រុម និងការបង្ហាញភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ
- ឱកាសក្លាយជាមន្ត្រីរាជការដោយផ្អែកលើសមត្ថភាព និងសមិទ្ធកម្មការងារ។

៤. កាលបរិច្ឆេទទទួលពាក្យ និងនីតិវិធីនៃការជ្រើសរើស

- បេក្ខជនទាំងពីរភេទត្រូវបំពេញពាក្យស្នើសុំតាមអាសយដ្ឋាន www.mptc.gov.kh/careers ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់**ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១៧:០០ នាទី**។
- បេក្ខជនត្រូវប្រឡងប្រជែងតាមរយៈវិញ្ញាសាសរសេរ ឬអនុវត្តកិច្ចការ ICT (ICT Assignment)
- បេក្ខជនដែលទទួលបានលទ្ធផលជាប់លើវិញ្ញាសាសរសេរ ត្រូវមកធ្វើបទបង្ហាញ ឬ មកសម្ភាសន៍ ដោយគណៈកម្មការរៀបចំការប្រឡងជ្រើសរើសអ្នកជំនាញ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកនាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាល នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តាមរយៈលេខទូរសព្ទ ០៩៦ ៧០០ ៦៦៦៦, ០១២ ៩២៥ ៩៣៥ និង ០៩២ ៨៨៦ ២៤២។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១

ស្កេន QR Code នេះដើម្បី
ចូលទៅកាន់អាសយដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

អ្នកជំនាញវិទ្យាសាស្ត្រទិន្នន័យ

(Data Science)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- សិក្សាស្រាវជ្រាវនិងវិភាគអំពីតម្រូវការទិន្នន័យ ដើម្បីប្រើប្រាស់ឬចម្រាញ់ជាព័ត៌មានបម្រើឱ្យគោលបំណងប្រកបដោយប្រសិទ្ធភាព
- រៀបចំកម្រងសំណួរនិងធ្វើការអង្កេតស្វែងរកគំហើញនៃទិន្នន័យ
- កំណត់វិធីសាស្ត្រក្នុងការប្រមូល ដំណើរការ និងសម្អាតទិន្នន័យដែលត្រូវការវិភាគ
- អភិវឌ្ឍវិធីសាស្ត្រគណនា(Algorithm)និងរបៀបព្យាករទិន្នន័យដែលប្រមូលបាន
- ប្រៀបធៀបវិធីសាស្ត្រគណនានិងរបៀបព្យាករផ្សេងៗគ្នា
- វិភាគទិន្នន័យនិងរៀបចំព័ត៌មានក្នុងទម្រង់សាមញ្ញទូទៅនិងងាយស្រួលយល់ លើប្រព័ន្ធនៃកម្មវិធីដែលកំពុងដាក់ឱ្យប្រើប្រាស់ និងទិន្នន័យទទួលបានពីប្រភពផ្សេងៗ
- វាយតម្លៃលើលទ្ធផលនៃការវិភាគទិន្នន័យ និងរុករកវិធីសាស្ត្រកែលម្អ
- ធ្វើសមាហរណកម្មទិន្នន័យជាមួយប្រព័ន្ធឬថ្នាលឌីជីថលនានា
- រៀបចំធ្វើការរក្សាទុកទិន្នន័យទៅតាមប្រភេទប្រកបដោយសុវត្ថិភាព
- ប្រើប្រាស់ឧបករណ៍ ប្រព័ន្ធ ឬកម្មវិធី ក្នុងការបកស្រាយសំណុំទិន្នន័យ ដោយផ្តោតលើនិន្នាការ និងលំនាំដែលអាចវាយតម្លៃ វិភាគ និងព្យាករលើការងារដែលស្ថាប័នប្រគល់ជូន
- សហការជាមួយក្រុមការងារពាក់ព័ន្ធដើម្បី អនុវត្តការងារវិភាគព្យាករទិន្នន័យឱ្យបានជោគជ័យ និងចូលរួមរៀបចំគោលនយោបាយពាក់ព័ន្ធនឹងការប្រមូល ការគ្រប់គ្រង ការសិក្សាស្រាវជ្រាវ និងការវិភាគព្យាករទិន្នន័យ
- រាយការណ៍អំពីកំហុសបច្ចេកទេសនានាដូចជា ការសរសេរកូដ និងបញ្ហាដែលទាក់ទងនឹងទិន្នន័យផ្សេងទៀត
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឡើងទៅ ស្របតាមជំនាញជ្រើសរើស
- មានបទពិសោធការងារយ៉ាងតិច ២ឆ្នាំ
- មានចំណេះដឹងលើ Statistical analysis, Machine learning, Big Data និង Data Structure
- មានបទពិសោធធ្វើការជាមួយ MySQL, PostgreSQL, MongoDB, SQL Server ឬ Hive
- មានបទពិសោធជាមួយ Programming Language ដូចជា R, Python, Java, C++ ឬ PHP
- មានសមត្ថភាពអាចធ្វើ Data extract, Clean, Structure និង Visualize
- មានសមត្ថភាពក្នុងការធ្វើការជាមួយភាគីពាក់ព័ន្ធដើម្បីវាយតម្លៃហានិភ័យដែលអាចកើតមាន។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

អ្នកជំនាញអភិវឌ្ឍសុសវែរ
(Software Development)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- សិក្សា រចនា អភិវឌ្ឍ និងគ្រប់គ្រងការអភិវឌ្ឍសុសវែរ ស្របតាមវដ្តអភិវឌ្ឍសុសវែរទៅតាមឧត្តមានុវត្តន៍
- ធ្វើតេស្តនិងវាយតម្លៃលើការអភិវឌ្ឍសុសវែរ
- រៀបចំក្បាទុកកូដរួម ដែលអាចប្រើប្រាស់សម្រាប់អភិវឌ្ឍសុសវែរផ្សេងៗ
- រចនាកូដឱ្យមានស្តង់ដារួម ហើយអាចដំណើរការដោយរលូន
- ផ្តល់គំនិតនិងយោបល់ ក៏ដូចជាផ្តួចផ្តើមអភិវឌ្ឍបន្តឬកែប្រែកម្មវិធីដែលមានស្រាប់ និងបង្កើតកម្មវិធីថ្មីៗ ដែលអាចជួយការងារឱ្យកាន់តែមានប្រសិទ្ធភាព
- ដោះស្រាយបញ្ហារបស់កម្មវិធី(Troubleshoot and Debug Applications)
- ធ្វើតេស្ត UI និងធានាប្រសិទ្ធភាពនៃប្រតិបត្តិការកម្មវិធីបង្កើតថ្មី
- រៀបចំប្រព័ន្ធសុវត្ថិភាព (Encryption and security) នៅលើកម្មវិធី
- រៀបចំនីតិវិធីធានាគុណភាពនៃការអភិវឌ្ឍសុសវែរ
- សិក្សាស្រាវជ្រាវ និងវិភាគអំពីនីតិវិធីការងារបច្ចុប្បន្ន ជាមួយនឹងវឌ្ឍនភាពបច្ចេកវិទ្យា ដើម្បីផ្តល់នូវគំនិតផ្តួចផ្តើមក្នុងការដោះស្រាយបញ្ហានានា
- រៀបចំឧបករណ៍ ប្រព័ន្ធ ឬកម្មវិធី សម្រាប់គាំទ្រដំណើរការអភិវឌ្ឍសុសវែរ
- ចូលរួមរៀបចំការបណ្តុះបណ្តាលអ្នកប្រើប្រាស់ ឬគ្រូបង្គោល
- សហការជាមួយក្រុមការងារពាក់ព័ន្ធ ដើម្បីអនុវត្តការងារអភិវឌ្ឍសុសវែរឱ្យបានជោគជ័យ និងចូលរួមរៀបចំគោលនយោបាយពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឡើងទៅ ដែលស្របតាមជំនាញជ្រើសរើស
- មានបទពិសោធការងារអភិវឌ្ឍកម្មវិធីយ៉ាងតិច ២ឆ្នាំ
- មានបទពិសោធធ្វើការជាមួយ MYSQL, SQL Server, PostgreSQL, SQLite, APIs and Back-end development
- ចំណេះដឹងលើភាសាកូដ ឬ Scripts មួយចំនួនដូចជា HTML, JavaScript and CSS, Ruby, Python and PHP, Java, C#, .Net និងFlutter Framework
- មានសមត្ថភាពក្នុងការធ្វើការជាមួយភាគីពាក់ព័ន្ធដើម្បីវាយតម្លៃហានិភ័យដែលអាចកើតមាន
- មានចំណេះដឹងលើវិធីសាស្ត្រក្នុងការវិភាគ និងអភិវឌ្ឍប្រព័ន្ធព័ត៌មាន
- មានវិញ្ញាបនបត្រពាក់ព័ន្ធនឹងការអភិវឌ្ឍសុសវែរកាន់តែប្រសើរ។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

អ្នកជំនាញសន្តិសុខសាយប័រ

(Cybersecurity)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- រៀបចំនីតិវិធីក្នុងការកំណត់ស្តង់ដារសន្តិសុខសាយប័រ នៅក្នុងក្រសួង ស្ថាប័ន
- ត្រួតពិនិត្យ និងរាយការណ៍ លើសកម្មភាពប្រតិបត្តិការប្រចាំថ្ងៃដែលពាក់ព័ន្ធនឹងសន្តិសុខសាយប័រ
- វិភាគ គ្រប់គ្រង និងការពារពីការគំរាមកំហែងផ្សេងៗ ដែលអាចប៉ះពាល់ដល់សន្តិសុខ និងសុវត្ថិភាព ហេដ្ឋារចនាសម្ព័ន្ធ នៃប្រព័ន្ធសន្តិសុខសាយប័រ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងស្ថាប័នផ្សេងៗទៀតដែលក្រសួងប្រគល់ជូន
- សិក្សា និងផ្តល់យោបល់លើហានិភ័យនៃគម្រោងផ្លាស់ប្តូរប្រព័ន្ធបណ្តាញថ្មី កម្មវិធីថ្មី និងការគ្រប់គ្រង ក៏ដូចជាការប្រើប្រាស់ប្រព័ន្ធទិន្នន័យរបស់អង្គភាពនីមួយៗ
- សិក្សា ស្រាវជ្រាវ និងអភិវឌ្ឍប្រព័ន្ធសន្តិសុខសាយប័រ ឱ្យស្របតាមស្ថានភាពជាក់ស្តែង និងស្តង់ដារ ព្រមទាំងតាមដានត្រួតពិនិត្យជាប្រចាំចំពោះការអនុវត្តតាមស្តង់ដារសន្តិសុខសាយប័រ ដែលបានដាក់ឱ្យប្រើប្រាស់
- រៀបចំកម្មវិធីវាយប្រហារប្រព័ន្ធសន្តិសុខសាយប័រសាកល្បងផ្ទៃក្នុងជាដំណាក់កាល ប្រចាំត្រីមាស ឆមាស ឬពេលវេលាកំណត់ណាមួយ ដើម្បីស្វែងរកចំណុចខ្វះខាតនូវស្តង់ដារសន្តិសុខសាយប័រ របស់ស្ថាប័ន ហើយអភិវឌ្ឍចំណុចខ្វះខាតឱ្យកាន់តែមានសុវត្ថិភាព
- សម្របសម្រួលក្នុងការរៀបចំឯកសារផ្សេងៗសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល ព្រមទាំងធ្វើជាគ្រូបង្ហាលផ្ទៃក្នុងលើប្រធានបទ សន្តិសុខសាយប័រ
- សហការជាមួយក្រុមការងារពាក់ព័ន្ធ ដើម្បីអនុវត្តការងារសន្តិសុខសាយប័រ ឱ្យបានជោគជ័យ និងចូលរួមរៀបចំគោលនយោបាយពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រព័ត៌មានវិទ្យា ឬសញ្ញាបត្រប្រហាក់ប្រហែល ឡើងទៅ
- មានចំណេះដឹងមូលដ្ឋានអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការរៀបចំប្រព័ន្ធសន្តិសុខសាយប័រ
- មានបទពិសោធពាក់ព័ន្ធការងារសន្តិសុខសាយប័រ យ៉ាងតិច២ឆ្នាំ
- មានជំនាញវិភាគដោយប្រើប្រាស់ Cybersecurity Tools មួយចំនួនមានដូចជា Burp Suit, Bettercap, Acunetix, Nexus និង Kali Linux
- មានចំណេះដឹងលើ Network, Application និង Mobile Security
- មានចំណេះដឹងលើដំណើរការនៃការធ្វើសវនកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងការគ្រប់គ្រងលើអភិបាលកិច្ច (Governance) ការវិភាគហានិភ័យ និងការរៀបចំឯកសារអនុលោមភាព (Compliance)
- មានចំណេះដឹងមូលដ្ឋានគ្រឹះទៅលើការប្រើប្រាស់ និងគ្រប់គ្រងប្រព័ន្ធប្រតិបត្តិការវីនដូរ (Windows) និងលីនុច (Linux)
- មានវិញ្ញាបនបត្រពាក់ព័ន្ធនឹងសន្តិសុខសាយប័រ កាន់តែប្រសើរ។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

អ្នកជំនាញបច្ចេកវិទ្យាក្លោដ

(Cloud Technology)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- រៀបចំនីតិវិធីក្នុងការកំណត់ស្តង់ដារប្រើប្រាស់បច្ចេកវិទ្យាក្លោដនៅក្នុងក្រសួង ស្ថាប័ន
- សិក្សា និងធ្វើការកែប្រែ ឬកែលម្អប្រព័ន្ធបច្ចេកវិទ្យាក្លោដដែលមានស្រាប់ ដើម្បីឱ្យសមស្របតាមការស្តង់ដារបច្ចេកវិទ្យាជាតិ និងអន្តរជាតិ និងផែនការគោលនយោបាយរបស់ក្រសួង
- អភិវឌ្ឍ និងរៀបចំដំណោះស្រាយពាក់ព័ន្ធនឹងបច្ចេកវិទ្យាក្លោដ ស្របតាមឧត្តមានុវត្តន៍
- គ្រប់គ្រង ត្រួតពិនិត្យ និងរាយការណ៍ លើសកម្មភាពប្រតិបត្តិការប្រចាំថ្ងៃដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាក្លោដ
- រចនា អភិវឌ្ឍ និងដាក់ឱ្យដំណើរការនូវប្រព័ន្ធម៉ូឌុលក្លោដ (Modular Cloud-based system)
- ជានាវុដំណើរការប្រកបដោយប្រសិទ្ធភាពនៃមុខងារផ្ទុកទិន្នន័យ មុខងារ Cloud-Computing និងមុខងារដំណើរការនៃបច្ចេកវិទ្យាក្លោដផ្សេងៗទៀត ស្របតាមស្តង់ដារបច្ចេកវិទ្យាជាតិ និងអន្តរជាតិ
- ចូលរួមរៀបចំការបណ្តុះបណ្តាលអ្នកជំនាញក្រសួងស្ថាប័ន
- សហការជាមួយក្រុមការងារពាក់ព័ន្ធ ជាពិសេសផ្នែកសន្តិសុខសាយប័រ ដើម្បីកំណត់អត្តសញ្ញាណ វិភាគ និងដោះស្រាយភាពងាយរងគ្រោះលើផ្នែកហេដ្ឋារចនាសម្ព័ន្ធក្លោដ និងបញ្ហាក្នុងការដាក់ឱ្យប្រើប្រាស់កម្មវិធីក្នុងបណ្តាញក្លោដ
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រព័ត៌មានវិទ្យា ឬសញ្ញាបត្រប្រហាក់ប្រហែល ឡើងទៅ
- មានចំណេះដឹងមូលដ្ឋានអំពីប្រព័ន្ធបច្ចេកវិទ្យាក្លោដ
- មានបទពិសោធពាក់ព័ន្ធបច្ចេកវិទ្យាក្លោដយ៉ាងតិច២ឆ្នាំ
- មានចំណេះដឹងពាក់ព័ន្ធ Continuous integration (CI) and continuous delivery (CD) systems, SysOps, ជាដើម
- មានវិញ្ញាបនបត្រពាក់ព័ន្ធ Azure, GCP (Google Cloud Platform) ឬ Amazon Web Services (AWS) កាន់តែប្រសើរ។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

អ្នកជំនាញមជ្ឈមណ្ឌលទិន្នន័យ
(Data Center)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- ត្រួតពិនិត្យ និងអនុវត្តការថែទាំបន្តនៅលើសេរ៉ូបកណ៍ (Server) និងឧបករណ៍បណ្តាញ
- ផ្តល់ការគាំទ្រ និងឆ្លើយតបទាន់ពេលវេលាពាក់ព័ន្ធនឹងបញ្ហារបស់សេរ៉ូបកណ៍ (Server) និងបណ្តាញ
- ការពារទិន្នន័យរបស់ក្រសួង ជាពិសេសការពារការឡើងកំដៅខ្លាំងនៃឧបករណ៍នៃមជ្ឈមណ្ឌលទិន្នន័យ
- វិនិច្ឆ័យផ្នែករឹង (Hardware diagnostics) និងជួសជុលផ្នែកដែលរងការខូចខាតឱ្យបានទាន់ពេលវេលា
- ត្រួតពិនិត្យដំណើរការបណ្តាញទាំងអស់ ដើម្បីធានាបាននូវលំហូរទិន្នន័យដោយរលូន
- សហការជាមួយក្រុមការងារពាក់ព័ន្ធ លើសុវត្ថិភាពអ៊ីនធឺណិត សន្តិសុខសាយប័រ និងប្រសិទ្ធភាពនៃបណ្តាញ
- ដំណើរការរៀបចំឯកសារ និងក្សាទុកកំណត់ហេតុព្រឹត្តិការណ៍
- ផ្តល់ការប្រឹក្សាលើការជ្រើសរើសឧបករណ៍មជ្ឈមណ្ឌលទិន្នន័យថ្មី
- សហការជាមួយក្រុមការងារពាក់ព័ន្ធ ដើម្បីអនុវត្តការងារមជ្ឈមណ្ឌលទិន្នន័យឱ្យបានជោគជ័យ និងចូលរួមរៀបចំគោលនយោបាយពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀតដែលម្នាក់គ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រព័ត៌មានវិទ្យា ឬសញ្ញាបត្រប្រហាក់ប្រហែល ឡើងទៅ
- មានចំណេះដឹងមូលដ្ឋានអំពីមជ្ឈមណ្ឌលទិន្នន័យ (Data Center)
- មានបទពិសោធពាក់ព័ន្ធមជ្ឈមណ្ឌលទិន្នន័យ យ៉ាងតិច២ឆ្នាំ
- មានជំនាញវិភាគដោយប្រើប្រាស់ Cybersecurity Tools មួយចំនួនមានដូចជា Nexus និង Kali Linux
- មានចំណេះដឹងស៊ីជម្រៅអំពីបរិស្ថាននៃមជ្ឈមណ្ឌលទិន្នន័យ សេរ៉ូបកណ៍ និងឧបករណ៍បណ្តាញ
- មានបទពិសោធក្នុងការដំឡើង ត្រួតពិនិត្យ និងថែទាំឧបករណ៍មជ្ឈមណ្ឌលទិន្នន័យ
- មានចំណេះដឹងលើ CompTIA ServerPlus, CompTIA Network ឬមានវិញ្ញាបនបត្រពាក់ព័ន្ធ CCNP កាន់តែប្រសើរ។

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

អ្នកជំនាញបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត

(Artificial Intelligence - AI)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- ជំរុញនិងផ្តល់ការគាំទ្រលើការប្រើប្រាស់ប្រព័ន្ធបញ្ញាសិប្បនិម្មិត សម្រាប់ការអភិវឌ្ឍប្រព័ន្ធឬផ្នែកបច្ចេកវិទ្យាឌីជីថលបម្រើសេវាសាធារណៈរបស់ក្រសួង និងស្ថាប័ន
- ស្រាវជ្រាវវិធីសាស្ត្រប្រើប្រាស់បញ្ញាសិប្បនិម្មិតដោយប្រើប្រាស់ប្រព័ន្ធរៀនតាមម៉ាស៊ីន និងវិភាគលើទិន្នន័យធំ
- អភិវឌ្ឍប្រព័ន្ធរៀនតាមម៉ាស៊ីន (Machine Learning) ការប្រើប្រាស់ទិន្នន័យធំ (Big-data) និងកម្មវិធីបញ្ញាសិប្បនិមិត្ត (AI) ដែលដំណើរការដោយស្វ័យប្រវត្តិ
- រៀបចំនិងគ្រប់គ្រងការអភិវឌ្ឍ និងហេដ្ឋារចនាសម្ព័ន្ធ AI នានារបស់ក្រសួង និងស្ថាប័ន
- បង្កើតគំរូ AI និងបណ្តុះបណ្តាលអ្នកពាក់ព័ន្ធអំពីអត្ថប្រយោជន៍ និងដាក់ឱ្យប្រើប្រាស់ AI
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបញ្ចូលទិន្នន័យ ការប្រើប្រាស់ និងការបំប្លែងទិន្នន័យសម្រាប់បញ្ចូលទិន្នន័យរក្សាទុក
- ចូលរួមរៀបចំការបណ្តុះបណ្តាលអ្នកជំនាញក្រសួងស្ថាប័ន
- សហការជាមួយក្រុមការងារពាក់ព័ន្ធ ដើម្បីអនុវត្តការងារបញ្ញាសិប្បនិម្មិតឱ្យបានជោគជ័យ និងចូលរួមរៀបចំគោលនយោបាយពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រព័ត៌មានវិទ្យា ឬសញ្ញាបត្រប្រហាក់ប្រហែល ឡើងទៅ
- មានចំណេះដឹងមូលដ្ឋានអំពីបញ្ញាសិប្បនិមិត្ត (AI)
- មានបទពិសោធពាក់ព័ន្ធបញ្ញាសិប្បនិមិត្ត (AI) យ៉ាងតិច២ឆ្នាំ
- មានជំនាញកម្រិតខ្ពស់ជាមួយនឹងការសរសេរកូដ Python, Java ឬ Golang
- មានចំណេះដឹងទូលំទូលាយនៃក្របខណ្ឌ Machine Learning, Deep Learning, C++ & R ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ គំរូទិន្នន័យ និងនិម្មាបនកម្មសូសវែរ (Software Architecture)
- មានចំណេះដឹងស៊ីជម្រៅផ្នែកគណិតវិទ្យា ស្ថិតិ និងក្បួនដោះស្រាយ (Algorithms)

* * * * * * *

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

អ្នកជំនាញបច្ចេកវិទ្យាប្លុកឆេន
(Blockchain Technology)

ក. តារកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- ស្រាវជ្រាវ រចនា អភិវឌ្ឍ និងសាកល្បងបច្ចេកវិទ្យាប្លុកឆេន (Blockchain Technology) ជាមួយនឹងប្រតិបត្តិការការងារ និងសេវាសាធារណៈនានារបស់ក្រសួង និងស្ថាប័ន
- ផ្តួចផ្តើមគំនិតនិងវាយតម្លៃកម្មវិធី និងបច្ចេកវិទ្យាថ្មីៗ សម្រាប់ប្រើប្រាស់ក្នុងបច្ចេកវិទ្យាប្លុកឆេន ហើយពិចារណារួមបញ្ចូលកម្មវិធី និងបច្ចេកវិទ្យាថ្មីៗដែលប្រើប្រាស់ប្លុកឆេនទាំងនោះជាមួយនឹងប្រតិបត្តិការការងារ និងសេវាសាធារណៈនានារបស់ក្រសួង និងស្ថាប័ន
- កំណត់តម្រូវការបច្ចេកវិទ្យាប្លុកឆេន និងមុខងារដែលរំពឹងទុក
- សហការជាមួយក្រុមការងារពាក់ព័ន្ធ អនុវត្តបច្ចេកវិទ្យាគ្រីបតូ (Cryptology) ចុងក្រោយបង្អស់ ដើម្បីការពារទិន្នន័យប្រតិបត្តិការឌីជីថលប្រឆាំងនឹងការវាយប្រហារតាមអ៊ីនធឺណិត និងការលួចយកព័ត៌មាន
- ការបង្កើនប្រសិទ្ធភាព និងការជានាកម្មវិធីប្លុកឆេន ដោយការរួមបញ្ចូលឧបករណ៍ និងបច្ចេកវិទ្យាថ្មីៗ
- ការចងក្រងឯកសារដំណើរការអភិវឌ្ឍបច្ចេកវិទ្យាប្លុកឆេនស្របតាមការអនុវត្តល្អបំផុតក្នុងការការពារទិន្នន័យ
- ធ្វើបច្ចុប្បន្នភាពចំណេះដឹងពាក់ព័ន្ធបច្ចេកវិទ្យាប្លុកឆេនថ្មីៗ និងវិធីសាស្ត្រ Cryptography ដើម្បីផ្សព្វផ្សាយដល់មន្ត្រី និងបុគ្គលិកក្នុងក្រសួង ស្ថាប័ន និងសាធារណជន
- សហការជាមួយក្រុមការងារពាក់ព័ន្ធ ដើម្បីអនុវត្តការងារប្លុកឆេនឱ្យបានជោគជ័យ និងចូលរួមរៀបចំគោលនយោបាយពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រព័ត៌មានវិទ្យា ឬសញ្ញាបត្រប្រហាក់ប្រហែល ឡើងទៅ
- មានចំណេះដឹងមូលដ្ឋានអំពីបច្ចេកវិទ្យាប្លុកឆេន
- មានបទពិសោធពាក់ព័ន្ធបច្ចេកវិទ្យាប្លុកឆេន យ៉ាងតិច២ឆ្នាំ
- មានជំនាញវិភាគដោយប្រើប្រាស់ C++, Java, និង Python ឬ GoLang, Rust និង Solidity
- មានចំណេះដឹងលើវិធីសាស្ត្រ Cryptography និងពិធីសារប្លុកឆេន (blockchain protocols)

****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

អ្នកជំនាញហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍

(Telecommunications Infrastructure)

ក. តារាកិច្ចនិងការទទួលខុសត្រូវសំខាន់ៗ

- សហការរៀបចំគោលនយោបាយ ផែនការជាតិ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិសាលគមន៍ ហ្វ្រេកង់ស៊ីទ្យុ និងផ្កាយរណប
- រៀបចំនិងកំណត់ស្តង់ដារបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ជាអាទិ៍បណ្តាញខ្សែកាប ស្ថានីយបង្គោលអង់តែន និងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍សម្រាប់ប្រើក្នុងអគារ (អាយ ប៊ី អេស)
- រៀបចំយន្តការពិនិត្យនិងវាយតម្លៃស្តង់ដារបច្ចេកទេស និងកំណត់គោលការណ៍ក្នុងការរៀបចំសណ្តាប់ធ្នាប់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍
- សហការជាមួយក្រុមការងារពាក់ព័ន្ធធ្វើការវិភាគទិន្នន័យ និងផ្តល់យោបល់ផ្នែកបច្ចេកទេស ដើម្បីដោះស្រាយបញ្ហាប្រឈម និងដើម្បីអាចលើកកម្ពស់គុណភាពសេវាទូរគមនាគមន៍
- សហការជាមួយក្រុមការងារពាក់ព័ន្ធធ្វើការសិក្សាស្រាវជ្រាវអភិវឌ្ឍ និងធ្វើនវានុវត្តន៍បច្ចេកវិទ្យាទូរគមនាគមន៍
- ប្រមូល និងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងការផ្តល់សេវាទូរគមនាគមន៍ ព្រមទាំងតាមដានការអនុវត្តស្តង់ដារបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍
- សហការរៀបចំវិធានការទប់ស្កាត់ការឆ្លងរំខានការទទួលស៊ីញ៉ាល់ហ្វ្រេកង់ស៊ីទ្យុទូទាំងប្រទេស
- សិក្សា ស្រាវជ្រាវបច្ចេកទេសផ្កាយរណប ផ្តល់យោបល់ពាក់ព័ន្ធនឹងការអភិវឌ្ឍលើវិស័យផ្កាយរណប
- អនុវត្តការងារផ្សេងទៀតដែលអ្នកគ្រប់គ្រងប្រគល់ជូន។

ខ. គុណវុឌ្ឍិ

- បេក្ខជនត្រូវមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រទូរគមនាគមន៍ ឬសញ្ញាបត្រប្រហាក់ប្រហែល ឡើងទៅ
- មានចំណេះដឹងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍
- មានបទពិសោធពាក់ព័ន្ធហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ យ៉ាងតិច២ឆ្នាំ
- មានចំណេះដឹងអំពីប្រព័ន្ធបណ្តាញជាច្រើនរួមមាន ខ្សែ ឥតខ្សែ បណ្តាញ LAN និង WAN ។
- មានការយល់ដឹងល្អអំពីឧបករណ៍ទូរគមនាគមន៍ ដូចជា ខ្សែកាបអុបទិក ផ្កាយរណប Router និង Switch។

****